Khmer Story Lovers

សម្រាប់អ្នកចូលចិត្តអាន និង តម្កើងសិល្បៈអក្សរសាស្ត្រខ្មែរ

# ក្អែក និងសំពោច

បទកាកគតិតែង ដំណាលតំណែង ដំណើរបក្សា ក្អែកគោកមួយនៅ
លើចុងព្រឹក្សា រស់ដោយសុខា ស្គាពរឯតតមោះ។
មានគ្រាមួយថ្ងៃ ក្អែកស្វែងចំណី តាមភូមិកៀនកោះ ឃើញអ្នកនិគម
ហាលនំទឹកដោះ ក្អែកអរហើរផ្លោះ ចុះចោះចឹកបាន។
កាងស្លាបហើរស្ទៅ តម្រង់ត្រង់ទៅ លំនៅស្មសាន ដល់ហើយចុះទំ
ទ្រទំនៃប្រាណ បែរមើលទីស្ថាន ដានដែលយាត្រា។
កាលនោះមានសត្វ សំពោចមួយជាត់ ស្វែងរកគោត្ត មកដល់យល់ក្អែក
ទំមែករុក្ខា មាត់ពាំនំណា ដាក់ដាចំណី។
សំពោចគិតថា អញនឹងចរចា បញ្ឆោរបក្សី ឱ្យវាហាមាត់
ភ្ញាត់ធ្លាក់ចំណី ជ្រុះមកដល់ដី អញធីវិញណា។
គិតហើយទើបពោល ជាពាក្យបញ្ជូល ទៅកាន់ក្អែកថា ក្អែកអើយអ្នកក្អែក
រូបឯកសោភា ចំពុះដូចជា ខ្ទែកែវមរកដ។
ពោមស្លាបស្រស់ស្រិល
រលង់ដូចនិល
រលើបម៉ត់ចត់
ចង្កេះសមទ្រង់
ជង្គង់សមបទ
រង់មុខសមមាត់
សមមានលក្ខិណា។



រូបអ្នកឧត្តម បើតាមក្បួនខ្ញុំ ទំនាយទាយថា នឹងបានសម្រេច
ជាស្តេចបក្សា តែស័ព្ទសព ពុំទាន់ប្រត្យ័ក្ស។
បើសិនអ្នកស្រែក ខ្ញុំព្ទសម្រែក សូរសមចំសក្តិ ខ្ញុំហ៊ានទំនាយ
ទាយថារូបអ្នក បានជាចមចក្ស កំពូលបក្សា។
ក្អែកឡើងអំនួត ព្ទគេសង្ហួត សរសើរអាត្មា
ចង់ឱ្យគេស្តាប់ សូរស័ព្ទសព ទើបឈរហើយហា មាត់ស្រែកចេញខ្មី។
ឯពំនាំនោះ ធ្លាក់ពីចំពុះ ជ្រុះមកដល់ដី សំពោចស្រើបស្រួល
ទទួលចំណី ហើយបែរស្រដី ចំអកបក្សា។
ក្អែកអើយចៅក្អែក អ្នកឯងបែងចែក ចំណីនេះណា យើងពេញគាប់ចិត្ត
ដ្បិតអ្នកយល់ថា យើងជាហោរា ទទួលខាន់ខៅ។
ជាហើយចៅក្អែក ប្រព្រឹត្តនេះឯក ឥតមានហ្មងសៅ
អ្នកឯងទៅរក មកទៀតណ៎ាចៅ ពីថ្ងៃនេះទៅ យើងបានពឹងផង។
ថាហើយសំពោច បែរប្រាណស្ទុះផ្លូច ចូលព្រៃដូចប៉ង
កាកោបង់នំ ក្រំចិត្តកន្លង ពុំដឹងទំនង ខ្មោចលងភក្សា។
និទានរឿងនេះ អញ្ជើញប្រាជ្ញបេះ ត្រិះមើលកិរិយា ក្អែកបង់ចំណី
ព្រោះក្តីប្រាថ្នា ក្នុងបសំសា ប៉ុយាសង្ហួត។
នរូអ្នកណា មានចិត្តប្រាថ្នា ចង់ឱ្យគេអួត
នឹងដូចក្អែកខ្មៅ ត្រូវគេសង្ហួត ឆោតឡើងអំនួត
បង់នំឯងអើយ។



សម្រង់ចាកនិទាន **គតិលោក**
រៀបរៀងដោយលោកឧកញ៉ា **សុត្តន្តប្រីជា ឥន្ទ**